**មាត្រា៣.**–សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកី
រដ្ឋមន្ត្រី និង រដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុករៀ
ខ្លួន អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ កញ្ញា ឆ្នាំ ១៩៩

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

អ៊ឹង ហួត ហ៊ុន សែ

* * *

**អនុក្រឹត្យ លេខ : ៤៨ អនក្រ.បក**

**ស្ដីពីការប្រើប្រាស់គណនីឯកជនរបស់បណ្ណាគារសាធារណៈ**

**សំរាប់ទូទាត់សងថ្លៃដីធ្លី-ផ្ទះសំបែងប្រជារាស្ត្រដែលមានការប៉ះពាល់**

**ដល់គំរោងសាងសង់ស្ពានឆ្លងទន្លេមេគង្គ ខេត្តកំពង់ចាម**

**និង សំណង់នានា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពី តែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោ ព្រះរាជក្រម លេខ១១ នស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤

– បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលលេខ ០១ សប្រក ចុះថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីឯកជនភាវូនីយកម្ម សហគ្រាសសាធារណៈ

– បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីបែបបទនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

– តាមសំណើរបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

មាត្រា១.– អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រើប្រាស់គណនី ឯកជនភាវូបនីយកម្ម សហគ្រាសសាធារណៈ ដែលត្រូវបានបង្កើតឡើង តាមមាត្រា៨៣ នៃច្បាប់ហិរញ្ញ វត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ លើមុខសញ្ញាដូចខាងក្រោម ÷

-ទូទាត់សងថ្លៃដីធ្លី-ផ្ទះសំបែងរបស់ប្រជារាស្ត្រ ដែលមានការប៉ះពាល់ដល់គំរោងសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គ ក្នុងខេត្តកំពង់ចាម

មានចំនួនទឹកប្រាក់1.400.000 USD(មួយលានបួនរយពាន់ ដុល្លារអាមេរិក)។

-ការងារជួសជុលចាក់បេទីម ដាក់ចិញ្ចើម និងជួសជុលបូមលាងបណ្តាញលូ ផ្លូវព្រះសុធារស ចាប់ពីមហាវិថីព្រះសីហនុ ដល់ មហាវិថីព្រះនរោត្តម

មានចំនួនទឹកប្រាក់ 188.500 USD (មួយរយប៉ែតសិបប្រាំបីពាន់ប្រាំរយ ដុល្លារអាមេរិក) ។

-ការងារជួសជុលក្រាលបេតុង បេទីមីណឺ ផ្លូវលេខ ២១៥ (នេហ៊ុរ) ពីមហាវិថីសហព័ន្ធរុស្ស៊ី ដល់ រង្វង់មូលអាងទឹកស្អាតអូឡាំពិក

មានចំនួនទឹកប្រាក់ 198.000 USD (មួយរយកៅសិបប្រាំបីពាន់ដុល្លារអាមេរិក)។

–សាងសង់ផ្លូវក្រាលកៅស៊ូ ពីផ្លូវជាតិដល់ទីរួមស្រុកសំបូរ ខេត្តក្រចេះ ប្រវែង ១៣ គីឡូម៉ែត្រ

មានចំនួនទឹកប្រាក់316.000 USD (បីរយដប់ប្រាំមួយពាន់ ដុល្លារអាមេរិក )

–សាងសង់សំណង់ទំនប់បង្ហៀរ ស្ទឹងជោរស្រុកកំចាយមារ ខេត្តព្រៃវែង

មានចំនួនទឹកប្រាក់ 532.500 USD ( ប្រាំរយសាមសិបពីរពាន់ប្រាំរយដុល្លារ អាមេរិក ) ។

**មាត្រា ២.**–សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែ កញ្ញា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

**អ៊ុង ហួត** **ហ៊ុន សែន**

## អនុក្រឹត្យ លេខ : ១៦៣ អនក្រ.តត

## ស្តីពីការជូនមេដាយ សហមេត្រី

## រាជរដ្ឋាភិបាល

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី... តាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

–បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

–តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សំរេច

**មាត្រា ១.**–ត្រូវបានប្រគល់មេដាយ សហមេត្រី តាមលំដាប់ថ្នាក់ ជាកិច្ចបច្ឆាមរណៈ ដល់សជនជាតិកូរ៉េខាងត្បូង ចំនួន ០៧រូប ដែលបានជួយអភិវឌ្ឍន៍លើវិស័យសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោមនេះ ÷

**ក–មេដាយ សេនា សហមេត្រី :**

–លោក BONG SEOK KIM